THE SCHOOL DISTRICT OF PHILADELPHIA

ជូនចំពោះ មាតាបិតា នៃវិទ្យាល័យ ណសអ៊ីស (Northeast) ជាទីគោរព៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ធ្វើការរាល់ថ្ងៃដើម្បីធានាថា សិស្ស និង បុគ្គលិក របស់យើងមានបរិយាកាសប្រកបដោយ សុវត្ថិភាព និង សុខភាពល្អ ដើម្បី សិក្សា និង ធ្វើការងារ។ ជួសមុខឱ្យក្រសួងអប់រំ ខ្ញុំសរសេរលិខិតនេះដើម្បីជម្រាបព័ត៌មានជូនដល់លោកអ្នកអំពីរបាយការណ៍នៃការខូចខាតកម្រាលឥដ្ឋនៅក្នុងបន្ទប់លេខ ២១- A ។ បន្ទប់នេះត្រូវបានគេប្រើជាការិយាល័យសម្រាប់បុគ្គលិករបស់វិទ្យាល័យ ណសអ៊ីស។ ការពិនិត្យកំណត់ត្រាឡើងវិញរបស់យើងបានបញ្ជាក់ថា កម្រាលឥដ្ឋ ដែលខូចខាតទាំងនោះមានផ្ទុកសារធាតុអាបេស្តូស (asbestos)។

បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងនេះភ្លាមៗ អ្នកសម្របសម្រួលផ្នែកថែរក្សាអាគារនៅតាមតំបន់ (FAC) បានចុះទៅសាលា ដើម្បីវាយតម្លៃ ស្ថានភាព និង ទំហំនៃការខូចខាត។ ជាលទ្ធផលនៃការទៅពិនិត្យរបស់ FAC បន្ទប់ ២១-A ត្រូវបានគេបិទជាបន្ទាន់។ នៅថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៩ អ្នកត្រួតពិនិត្យបរិស្ថានដែលមានអាជ្ញាប័ណ្ណ នៃភាគីទីបី បានបញ្ចប់ការវាយតម្លៃនៃការខូចខាត និងបានបង្កើតគម្រោងការងារ ដើម្បី កាត់បន្ថយ និង យកឥដ្ឋចេញ។ អ្នកត្រួតពិនិត្យក៏បានពិនិត្យមើលកន្លែងផ្សេងៗទៀតនៃអាគារនៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៩ ដើម្បីធ្វើកំណត់ហេតុអំពីការខូចខាតសម្ភារៈដែលមានសារធាតុអាបេស្តូស។ លទ្ធផលនៃការត្រួតពិនិត្យបានរកឃើញកន្លែងចំនួន ៦ បន្ថែមទៀតដែលមានឥដ្ឋខូចខាត និង ប្រពន្ធ័ស្រោបបំពង់ទឹក ដែលមានផ្ទុកសារធាតុអាបេស្តូស។

**ផ្អែកលើការខូចខាតដែលគេបានរកឃើញ ក្រសួងអប់រំមិនជឿថាមានគ្រោះថ្នាក់ភ្លាមៗ ឬ នឹងបណ្តាលឱ្យមានគ្រោះថ្នាក់ចំពោះ សិស្ស និង បុគ្គលិក នៅក្នុងអាគារនោះទេ។ ទោះជាយ៉ាងណាក៏ដោយ យើងបានចាប់ផ្តើមធ្វើការជាមួយ លោកនាយកសាលា គ្រោវឌ័រ (Crowder) ដើម្បីបង្កើតកាលវិភាគដើម្បី ជួសជុល ឬ យកចេញ នូវសម្ភារៈដែលខូចខាត។** គេនឹងចែករំលែកផែនការនេះជាមួយ នាយកផ្នែកបរិស្ថាន របស់សហព័ន្ធគ្រូបង្រៀននៃទីក្រុងហ្វីឡាដែលហ្វ្យា។ ដោយសារមានការចុះឈ្មោះចូលរៀនយ៉ាងច្រើននៅវិទ្យាល័យ ណសអ៊ីស និងចំនួន សកម្មភាព និង កម្មវិធី នៅក្នុងអាគារ ក្រសួងនឹងកំណត់ពេលវេលាដើម្បីកាត់បន្ថយ នៅចុងសប្តាយវែងដែលមានថ្ងៃបុណ្យឈប់សម្រាក បុណ្យថ្លែងអំណរគុណ និង វិស្សមកាលនាសិសិររដូវ នៅពេលដែលសិស្សមិននៅក្នុងអាគារ។ ការងារនឹងចាប់ផ្តើមនៅចុងសប្តាហ៍នៃថ្ងៃបុណ្យអតីតយុទ្ធជននេះ ដើម្បីជួសជុលកម្រាលឥដ្ឋដែលខូចខាត នៅតាមផ្លូវដើរនៅក្នុងអាគារ និង នៅក្នុងបន្ទប់លេខ ២១-A ។

ច្បាប់ចម្លងនៃរបាយការណ៍ត្រួតពិនិត្យមាននៅក្នុងសៀវភៅរបស់ AHERA នៅក្នុងការិយាល័យសាលា ហើយគេក៏នឹងចុះផ្សាយនៅក្នុងវិបសៃរបស់ NEHS និងវិបសៃរបស់ក្រសួងអប់រំ (www.philasd.org) ផងដែរ។

សុវត្ថិភាពរបស់ សិស្ស និង បុគ្គលិក នៅតែជាអាទិភាពខ្ពស់បំផុតរបស់យើង។ យើងខ្ញុំអរគុណចំពោះ ការយោគយល់ ការអត់ធ្មត់ និង ការសម្របសម្រួល របស់លោកអ្នក។ លោកអ្នកអាចទាក់ទងទៅ ការិយាល័យ គ្រប់គ្រង និង បម្រើផ្នែកបរិស្ថាន លេខ ២១៥-៤០០-៤៣៣០ បើលោកអ្នកមាន សំណួរ មតិយោបល់ ឬ បារម្ភអ្វីផ្សេងទៀត។

ដោយសេចក្តីគោរពរាប់អាន

Danielle Floyd
នាយកប្រតិបត្តិ